**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ. ធ៧.០២៤...១៧១៨.ឆ.ន

ថ្ងៃ ពុធ ២ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែសីហា ឆ្នាំ២០២៤

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា**
**គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ ករណីបន្តអនុវត្តកម្រិតអនុបាតទ្រនាប់ដើមទុនខនស៊ើរវេសិន អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ និងអនុញ្ញាតឱ្យមានការរៀបចំឥណទានឡើងវិញជូនអតិថិជន។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ឱ្យបានជ្រាបថា ដើម្បីផ្តល់លទ្ធភាពបន្ថែមឱ្យគ្រឹះស្ថានបញ្ចេញឥណទាន សំដៅចូលរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ ធនាគារជាតិនៃកម្ពុជា សម្រេចអនុញ្ញាតឱ្យគ្រឹះស្ថាន៖

ក. បន្តអនុវត្តអនុបាតទ្រនាប់ដើមទុនខនស៊ើរវេសិន ត្រឹមកម្រិត ១,២៥% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

ខ. បន្តអនុវត្តអត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ ត្រឹមកម្រិត ៧% រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និង

គ. រៀបចំឥណទានឡើងវិញជូនអតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុបណ្តោះអាសន្ន ស្របតាមលក្ខខណ្ឌកំណត់ក្នុងសារាចរណែនាំដោយឡែក។

គ្រឹះស្ថានត្រូវបញ្ចេញឥណទានប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាបាននូវកំណើនប្រកបដោយចីរភាព និងរួមចំណែករក្សាស្ថិរភាពប្រព័ន្ធធនាគារទាំងមូល។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានដោយយកចិត្តទុកដាក់លើស្ថិរភាពប្រព័ន្ធធនាគារ និងប្រសិទ្ធភាពនៃការអនុវត្តវិធានការអនុគ្រោះខាងលើ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា ទទួលនូវការរាប់អាន អំពីខ្ញុំ។

**ត.ប. ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**គិត សុវណ្ណារិទ្ធ**